លើពីសរាំងវត្តសាលអមដោយបុប្ផស្រស់ៗ និងភ្លេងរបាំត្បូរអោយសប្បាយអ្វីម្លេះទេ !។

-ពួកយើង ចេញដំណើរ !(សម្លេងបញ្ជារបស់នាយរាម)

ច្រកទ្វាររនាំងរោងដាក់ឡានបើកឡើង.....រថយន្តហុងដាពណ៌ខ្មៅរលើបមួយបើកបរដោយនាយរាមនិងគូកនរបស់គេចាកចេញសន្សឹមៗពីភូមិគ្រឹះបន្តិចមកក៏បោះពួយលើវិថីរលោងស្រិលទៅចាត់ស្រមោល ។

.................................

ភ្លៀងរលឹមស្រិចៗ អាកាសធាតុត្រជាក់ផ្ទៃមេឃងងឹតស្ងួនស្ងាត់សុងព្រះច័ន្ទនិងហ្វូងផ្កាយតារាពុំបានបញ្ចេញពន្លឺបំភ្លឺផែនដីនោះទេ ។តែទោះបីជាគ្មានពន្លឺព្រះច័ន្ទក្តី,ត្រឡោកបែក ក៏គង់នៅមានពន្លឺអំពូលភ្លើងពណ៌ក្រហមព្រឹមៗ តាមផ្ទះសំណាក់នានាគ្រាន់បញ្ឆោតដួងចិត្តអ្នកទេសចររាត្រីទាំងឡាយ អោយនឹកមមៃចង់ចូលកំសាន្តលំហែកាយក្នុងវិមានផ្ទះស្លឹកទាំងនោះ ។

ម៉េងបើកឡានទៅមកពីរបីសា តាមបណ្តោយផ្លូវត្រឡោកបែកភ្នែកគន់រំពៃរកមើលក្លយគេទាំងពីរ ។ គេសំរេចចិត្តបញ្ឈប់ឡាននៅមុខផ្ទះសំណាក់មួយដែលមានដាក់យីហោតូចមួយថា"កោសខ្យល់ ជប់ខ្យល់ ម៉ាស្សា"

សារ៉ាន់អង្គុយក្បែរម៉េងពោលទៅកាន់ម៉េងថា ៖

-បងម៉េង ! កន្លែងនេះរញ៉ីរញ៉ៃណាស់ !ខ្ញុំមិនដែលមកជាន់ទីនេះម្តងណាសោះមើលហ្នំពួកគេរាក់ទាក់បក់ដៃហៅយើងដោយក្តីរាប់អានខ្លាំងណាស់ ! ខ្ញុំដូចជាអៀនខ្លួនដល់ហើយ !។

KHMER STORY LOVERS
សម្រាប់អ្នកចូលចិត្តអាន និង តម្កើងសិល្បៈអក្សរសាស្ត្រខ្មែរ

ម៉េងលឺសារ៉ាន់ពោលដូច្នោះក៏តបថា ៖

-ខ្ញុំក៏ដូចឯងដែរមិនធ្លាប់មកទីនេះទេ .ទោះបីខ្ញុំនៅភ្នំពេញជាង១៨ឆ្នាំហើយក្តី។ដោយសារយើងមានការចាំបាច់ណាស់ទើបយើងបានមកស្គាល់ទីនេះ ។ តែយើងគួរតែដឹងគួរតែឃើញនិងភ្នែកផងដែរ ថាតើជីវិតនៅទីនេះគេរស់នៅដូចម្តេច ?ព្រោះវាជាជ្រុងមួយនៃសង្គមបច្ចុប្បន្ន ។សព្វថ្ងៃមនុស្សមានសេរីភាពស្វែងរកសេចក្តីសប្បាយតាមគ្រប់រូបភាពទាំងអស់ តែគួរយើងពិចារណាថាតើយើងគួរសប្បាយបែបណាដែលមិននាំទុក្ខលំបាកដល់ខ្លួនយើងនិងក្រុមគ្រួសារ ។ តែណ្ហើយពេលនេះមិនមែនជាពេលយើងត្រូវពិចារណារឿងសីលធម៌សង្គមទេ...ហ្នំឯងមើលមីងម្នាក់នោះគាត់ដើរមកហើយ !

-លោកប្រុសអញ្ជើញចូលពិសារអីសិន ! (មីងមិនស្គាល់ឈ្មោះដើតតាមកញ្ចក់ឡានសួរអ្នកទាំងពីរដោយបញ្ចេញផ្កាញញឹមស្រស់ )

សារ៉ាន់ប្រញាប់ឆ្លើយតួរសមវិញ ៖

-បាទមីង ខ្ញុំទទួលទានរួចហើយ !

ម៉េងប្រញាប់កេះសារ៉ាន់ប្រាប់ថា ៖

-កុំចាំបាច់តួរសមជាមួយគាត់ច្រើនពេកប្រយ័ត្នជាប់សំជីវីវរឥឡូវហើយ ឯងអង្គុយអោយស្ងៀមទុកខ្ញុំសួរគាត់(ម៉េងសួរទៅមីងនោះថា)៖

-មីងនៅម្តុំនេះមានស្គាល់មនុស្សម្នាក់ឈ្មោះខ្មៅទេ ? គេហៅវាថា "អាខ្មៅៗ" មាឌមាំសម្បុរខ្មៅជិះម៉ូតូវីវ៉ា ?។

មីងឈប់រកនឹកបន្តិចក៏តបវិញថា ៖

-អាខ្មៅ ? ហ៊ីមិនស្គាល់អាខ្មៅកូនតាខ្វាន់នៅផ្ទះខាងនុះ ! ល្ងាចមិញវាប្រកាប់ប្រចាក់ជាមួយពួកម៉ាកវា ធ្លាយជញ្ជាំងផ្ទះឪវាដេញវាយមួយដងរែកវាជិះម៉ូតូរត់ទៅ

ណាចាត់ហើយ !

-មីងជួយហៅពូខ្នាន់អោយខ្ញុំបន្តិចបានទេ ?

-ចាំមានអី (មីងនោះដើរទៅស្រែកហៅតាខ្នាន់)

-តាខ្នាន់អើយមានភ្ញៀវមករក !

តាខ្នាន់ដើរមកអើតមើលក្នុងរថយន្ត នឹកថាជាម៉ូយមករកជួលផ្ទះសំណាក់ គាត់ខំអររព្រោះបានម៉ូយជុំជិះសុទ្ធតែឡានបីកទំនិញ ។

-តាឈ្មោះតាខ្នាន់ឪពុកខ្មៅមែនទេ ?(ម៉េងសួរតាខ្នាន់)

-បាទខ្ញុំហ្នឹងហើយ !

-តាមានដឹងថាប្អូនខ្មៅ និងពួកម៉ាកគេដែលឈ្លោះគ្នាពីល្ងាចនោះចាកចេញពីទីនេះទៅកាន់កន្លែងណាទេ ?

-លោកសួររកអាកូនចិញ្ចឹមបំបង់បាយនោះឬ ? ខ្ញុំមិនដឹងវាទៅណាទេ ! ខ្ញុំមិនត្រូវការដឹងលឺពីវាទៀតទេ !(ថាហើយតាខ្នាន់ដើររ៉ុយចេញទៅ)

នាយម៉េងប្រញាប់ចុះពីឡានតាមអង្វរតាខ្នាន់ :

-នេះជារង្វាន់សំរាប់តា ( នាយម៉េងដកប្រាក់ ១ម៉ឺនរៀល ១សន្លឹកហុចអោយតាខ្នាន់ តាខ្នាន់ប្រកែកមិនទទួលហើយមើលមុខម៉េងរួចសួរថា ៖

-លោករកវាធ្វើអី ?

-ខ្ញុំជំរាបតាតាមត្រង់ទៅចុះ ខ្ញុំមិនមែនមករកប្អូនខ្មៅទេ គឺខ្ញុំមករកក្មួយខ្ញុំដែលដើរជាមួយប្អូនខ្មៅនោះ !នេះប្រាក់សូមលោកតាកុំទើសទាល់អីយករង្វាន់នេះទៅហើយសូមប្រាប់ខ្ញុំផងថាតើពួកគេនៅទីណា ។

ម្តងនេះតាខ្នាន់ទទួលលុយយ៉ាងលឿនហើយដាក់ក្នុងហោប៉ៅអាវទើបចេញវាចាៈ



_លោកចង់រកពួកគេ ត្រូវទៅរកនៅវីឡាឯទួលគោកពួកគេតែងជួបជុំគ្នានោះទីនោះ

_ទៅវីឡាទទួលគោកនោះតាមផ្លូវណាទៅតា ?

_លោកបើកឡានតាមផ្លូវនេះចុះទៅក្រោម ហើយមើលទៅខាងជើងមានផ្ទះមួយធំរួចបត់ស្តាំ . បត់ស្តាំហើយបត់ឆ្វេង រួចចុះត្រង់ទៅមុខ . ចុះត្រង់ទៅមុខហើយបត់ឆ្វេងវិញ . ងាកស្តាំហើយបត់ឆ្វេងរួចទៅមុខដល់ហើយ.......

_ស្លាប់ហើយរកម៉េចឃើញទៅតា !(តាខ្នាន់ធ្វើញឹមៗមើលមុខម៉េងព្រោះគាត់ចង់បានអ្វីម្យ៉ាងថែមទៀត)។

_ខ្ញុំចង់អោយតាជួយជូនខ្ញុំទៅរកវីឡានោះបន្តិចបានទេ !

_ហឺមិនបាន ! តែខ្ញុំមិនអាចទៅចោលមុខរបរខ្ញុំបានទេ ព្រោះទីនេះដូចលោកឃើញស្រាប់ហើយ ដណ្តើមម៉ូយគ្នាខ្លាំងណាស់ ។

ម៉េងយល់ចំណុចចិត្តតាខ្នាន់ ក៏ហុចប្រាក់ ១ម៉ឺនរៀលទៀតអោយតាខ្នាន់ជាសគុណ ។ តាខ្នាន់ញញឹមព្រាយទទួលរាក់ទាក់ធានាខ្លួនជូនទៅ ។

នាយម៉េងបានអ្នកនាំផ្លូវចំណានហើយ ក៏ចេញដំណើរមកដល់វីឡានាយរាម ។ ពួកគេជួបពូភ្លឹងឈរជក់បារីនៅក្លោងទ្វារខាងក្រៅ ពូភ្លឹងឃើញតាខ្នាន់ស្គាល់ច្បាស់ជាបងធម៍ខ្លួនក៏សួរថា ៖

_បងខ្នាន់ទៅណាមកណាទាំងយប់ ?

_អញមករកអាខ្មៅ វាមាននៅទីនេះទេ ?

_វាមិននៅទេ !វានាំគ្នាទៅចូលបារអស់ហើយ !លោកបងដឹងស្រាប់ហើយយប់ថ្មើរនេះពួកអាក្មេងៗអស់នេះមិនដែលនៅផ្ទះទេ ចង់រកវាទៅរកនៅបារទៅបានឃើញ។

-វាចំណាំទៅបារណា ?(តាខ្វាន់សួរបញ្ជាក់ពូគ្លីង)

-ទេ...លីថាវាទៅបារស្អីនោះ....ដូចជាស្ថានសួគ៌ បាំនប្រែតអីម៉ែចវា ខ្ញុំមិនចាំឈ្មោះខាងដើមនិងខាងចុងលីតែថាឋានសួគ៌ៗ ។

ម៉េងលួកមាត់សួរពូគ្លីងថា ៖

-ពូក្នុងចំណោមមិត្តភក្តិអាខ្មៅ តើមានបងប្អូនប្រុសពីរនាក់ឈ្មោះម៉ូដែលនិងម៉ូដែនទេ ?

-ក្មួយម៉ូដែល និងម៉ូដែនក៏នៅក្នុងចំណោមអាខ្មៅដែរ ។កាលពីក្បាលល្ងាចពួកគេប្រយុទ្ធដណ្តើមកាំភ្លើងគ្នាជាមួយអាខ្មៅក្មួយខ្ញុំនេះ ក្រោយមកក៏ត្រូវរ៉ូវគ្នាវិញហើយជិះឡានទៅបាត់អស់ទៅ....។ក្មេងៗអស់នេះវាតែអីចឹងត្រូវវាយគ្នាវាវាយភ្លាម រួចពីវាយគ្នាវានាំគ្នាចូលបារផឹកស៊ីដល់យប់ជ្រៅបានមកផ្ទះ ។ជួនកាលវាមិនទាំងចូលផ្ទះផងវានាំគ្នាទៅដេកផ្ទះសង្សារវាឯណាឯណីមិនដឹងជាស្អីទេ ។និយាយអីចឹងក្មួយឯងត្រូវជាយ៉ាងម៉េចនិងក្មួយម៉ូដែលដែរ ?(តាគ្លីងសួរម៉េង)

-ខ្ញុំត្រូវជាមារបស់ម៉ូដែលនិងម៉ូដែន ខ្ញុំមកតាមរកក្មួយខ្ញុំអោយត្រឡប់ទៅផ្ទះវិញព្រោះម៉ាក់គេរង់ចាំមើលផ្លូវឯផ្ទះ ។

-ក្មួយចង់រកពួកគេ បើកឡានរកតាមបារទៅ . នៅចាំទីនេះមិនងាយបានជួបគេទេ ។

នៅពេលអ្នកទាំងពាកំពុងនិយាយជាមួយពូគ្លីងពូជិមដែលស្រវឹងស្រាដេកលើឡានខាងក្រោយ ស្រាប់តែភ្ញាក់សើងមម៉ើងឡើង ស្ទុះចេញពីក្រណាត់តង់ដំបូលឡានទទឹកក្បាលជោក . ទឹកភ្លៀងហូរសើមទាំងខោអាវគាត់ជោគអស់ទាំងខ្លួនប្រាណ ។ ពូជិមខំសម្លឹងមើលទាំងងងឹតមិនដឹងជាឡានដឹកគាត់មកដល់ទីណាហើយទេ ព្រោះអំណាច



ជាតិស្រវឹងធ្វើអោយគាត់ដេកលក់រហូតមក ។ប៉ុន្តែ.គាត់ស្រាប់តែមានអារម្មណ៍ថាឈឺពោះយ៉ាងខ្លាំងហើយចង់ក្អួតផង ពោះគាត់ក្តៅគគុកគាត់អស់កម្លាំងយ៉ាងខ្លាំង ។ គាត់ម៉ូម្នាស្ទុះចុះពីឡានរត់ឆ្លងផ្លូវទៅអង្គុយសំកុកបត់ជើងនៅគុម្ពផ្កាមួយគុម្ពធំដែលដុះក្បែរផ្លូវ ។ គាត់រាគផងក្អួតផង ប្រកាច់ប្រកិនម្នាក់ឯងរកស្រែកហៅអ្នកណាជួយក៏មិនរួចព្រោះហេវអស់កម្លាំង ។

ចំណែកម៉េង និងសាវ៉ាន់ពេលយកពត៌មានពីតាគ្លីងរួចរាល់ហើយ ក៏នាំតាខ្វាន់ឡើងឡានប្រញាប់ប្រញាល់ចាកចេញពីទីនោះ ដោយមិនបានដឹងថាពូជិមចុះពីលើឡានទេ ។

ឯពូជិមឃើញឡានទៅចោល ខំបក់ដៃស្រែកហៅដែរ តែគ្មានអ្នកណាលឺព្រោះសម្លេងគាត់ខ្សាវៗណាមួយស្បៀកខោមិនទាន់ផង ។ឡានក៏ទៅចោលបាត់ទៅ ។ ពេលឡានទៅបាត់ពូជិមស្លៀកខោរួច ដើរមកឈរកណ្តាលផ្លូវ យកដៃម្ខាងអោបពោះដៃម្ខាងដាល់មេឃជើងម្ខាងធាក់ដីខឹងសម្បារខ្លាំងណាស់ស្រែកឡូឡាទាល់តែភ្ញាក់ផ្អើលដល់ពូគ្លីងដើរមកសួរនាំហេតុការណ៍ ។

ពូគ្លីងសួរពូជិមថា ៖

-លោកបងមកពីណាទៅណា បានជាមកចេញយក្សល្ងានបាសាក់នៅកណ្តាលផ្លូវទាំងយប់ងងឹតឈឹងអីចឹង ?

-អាឡានចង្រៃនោះវាទៅចោលខ្ញុំ !(ពូជិមចង្អុលទៅទិសដែលឡានចេញទៅចោលគាត់)

ពូគ្លីងសួរនាំមួយសន្ទុះទើបដឹងថា ពូជិមមកជាមួយឡានម៉េង ហើយត្រូវឡានចេញចោលបាត់ទៅ ព្រោះគាត់រវល់ទៅបត់ជើងធំ ។ ពូគ្លីងក៏នាំពូជិមដែលទ្រមខ្លួន

ដោយស្រាច្រើទុកខ្លាំងទៅសំរាកក្នុងផ្ទះគាត់បណ្ដោះអាសន្នសិន ទំរាំព្រឹកព្រាងស្វាង ស្ងួរិយាសីមអោយគាត់យាត្រាទៅផ្ទះគាត់វិញ ។

ម៉េងបើកឡានយកតាខ្វាន់ទៅផ្ទះគាត់ , ហើយនាំសាវ៉ាន់ទៅមើលតាមរង្គសាលនានាក្នុងក្រុង ។អ្នកទាំងពីរគ្រាន់តែអើតមើលពីលើឡាន តែពុំបានចុះទៅមើលក្នុងបារទេព្រោះពួកគេសុទ្ធតែអ្នករបួសជើងរបួសជើង ។ សាវ៉ាន់រុំដៃព្យួរនៅឡើយ ឯម៉េងរុំជើងឡើងធំស្ពឹងពុំអាចធ្វើដំណើរបានរហ័សរហួនទេ ។

ឈានដល់ពាក់កណ្ដាលយប់ទៅហើយការដើររកគ្មានបានលទ្ធផលអ្វីសោះឡើយ។ អ្នកទាំងពីរនឿយហត់យ៉ាងខ្លាំង ណាមុខរបួសដេរឈឺចាប់យ៉ាងពិបាកទ្រាំ ព្រោះពុំបានសំរាកសោះតាំងពីរព្រឹកមកចេះតែមានរឿងរ៉ាវរវល់រហូត ។

ម៉េងនិងសាវ៉ាន់ ក៏សំរេចចិត្តថាត្រឡប់ទៅសំរាកនៅផ្ទះរៀងៗខ្លួនសិនចាំព្រឹកស្អែកចេញដំណើររកតទៅទៀត ។

ម៉េងបើកឡានជូនសាវ៉ាន់មកឃ្លាំងវិញ . ពេលមកដល់ឃ្លាំងសាវ៉ាន់ចុះពីលើឡានទៅដាស់ពូជិមដែលគេនឹកថាគាត់កំពុងសំរាកនៅក្រោយឡាននោះ ។

ស្រាប់តែចាត់ពូជិមមិនឃើញនៅលើឡាន ឃើញតែក្រណាត់តង់កៅស៊ូដំបូលឡានទទេ ។ សាវ៉ាន់ស្រែកប្រាប់ម៉េងថា ៖

-បាត់ពូជិមទៅណាហើយបងម៉េងអើយ !

-ក្រែងគាត់ដេកលើឡានហេតុអីបានជាបាត់គាត់គួរអោយឆ្ងល់ គាត់លោតចុះពីលើឡានពីកាលណាហ្ន៎ ?

សាវ៉ាន់ដើរទៅអើតមើលផ្ទះពូជិម ហើយសួរមីងសៅ . មីងសៅក៏ថារអត់ឃើញគាត់មកផ្ទះទេ ដូច្នេះពូជិមទៅណា !

មីងសៅស្រាប់តែនឹកឃើញថា : ប្ដីគាត់ចាត់ខ្លួននេះគ្មានទៅណាក្រៅពីទៅកំដរកូនគាត់ដេកពេទ្យទេ ព្រោះពីរសៀលពូជិមបានប្រាប់មីងថា ល្ងាចនេះគាត់ទៅសំរាកនៅឯពេទ្យមើលកូនគាត់ កុំចាំផ្លូវគាត់អី ។

ទាំងអស់គ្នាក៏អស់សង្ស័យរឿងពូជិម ហើយនាំគ្នាទៅសំរាកយកកម្លាំងដើម្បីធ្វើការថ្ងៃស្អែកទៀត ។

..............................

ទោះបីមានភ្លៀងរលឹមស្រិចៗក៏ដោយ រង្គសាលរាត្រីឋានសួគ៌ាក៏អាចអូសទាញបានភ្ញៀវច្រើនកុះករដែរ ។

នៅខាងក្នុងរង្គសាលដែលមានសភាពស្ទើរងងឹតស្ទើរភ្លឺ ពួកអ្នករាំកំពុងលោតចាក់ក្បាច់តាមសង្វាក់ភ្លេង។ឯអ្នកផឹកស៊ីតាមតុនានាហាក់ដូចជាពុំបានគិតគូររាប់សំបកកំប៉ុងស្រាបៀរដែលចោលគរក្រោមតុនោះឡើយ ព្រោះនារីឡង់សេស្រាបៀពីរទៅបីនាក់ដែលឈរបំរើក្បែរនោះ ពូកែបំផុតខាងគាស់កំប៉ុងស្រាបៀរថ្មីទៀតចាក់បំពេញកែវអ្នកផឹកអោយនៅតែពេញជាប់ជានិច្ចមិនអោយខ្វះកន្លះឡើយ ។ នៅតុម្ខាងឯណោះក្បែរពីសរាំ មាននារីដ៏ស្រស់ប្រិមប្រិយ២នាក់កំពុងអង្គុយសាសងគ្នា និងកាន់កែវទឹកផ្លែឈើម្នាក់មួយកំប៉ុងផង ។

-អាចា ! ឯងឥឡូវដូចជាប្លែកណាស់រ៉ុយតាំងពីបានទាក់ទងអ្នកកម្លោះកូនចៅកែនោះ សម្បូរលុយចាយដល់ហើយ ! អាវឯងឃើញតែកាត់ថ្មីជាប់ មាសប្រាក់ឯងក៏មានពេញការបួបទៀត !។

-ហ៊ឹយ ! គ្មានអ្វីគួរអោយអស្ចារ្យទេបងនីណាអើយ ! យើងមកនៅទីនេះទៅហើយ បើមិនរកលុយរកមាសប្រាក់តើរកស្អីទៅវិញ ?

_អើ ! ប៉ុន្តែឯងវាគ្រាន់បើជាងខ្ញុំ ! ធាឯងនៅក្មេងរូបក៏ស្អាត អ្នកកម្លោះនោះគេមិនស្តាយលុយចាយមកលើឯងទេឯរូបខ្ញុំវិញមិនសូវមានសម្រស់ ទាក់បានតែតួរាយរងទោះបីធ្លាខំធ្វើមុខកែច្រមុះកែភ្នែកយ៉ាងណាក៏នៅតែមិនដល់ឯងដែរ ! អើ !និយាយអីចឹងអ្នកប្រុសឯងយប់នេះដូចជាមិនឃើញមកអ៊ីយ ?

_ទុះហ្ន៎បងនីណាគេមកហើយតើ នៅក្នុងបន្ទប់កញ្ចក់ឯណោះ !

_អើមែនអ៊ីយ ! ហេតុអីឯងមិនទៅរកគេ ?

_យើងជាស្ករចាំបាច់ដើរទៅរកស្រមោចធ្វើអី ?

នៅក្នុងបន្ទប់កញ្ចក់ឯណោះ បុរសនារីមួយក្រុមទៀតកំពុងព្រោកប្រាជ្ញនៅជុំវិញតុដែលពោរពេញដោយម្ហូបអាហារ ដៃកាន់ស្រាបៀរ និងទឹកក្រូចលើកទង្គិចគ្នាសើចក្អាកក្អាយ ។

នាយរាមដែលតាមទម្លាប់ តែងតែជាអ្នកចាត់ចែងកម្មវិធីផឹកស៊ីនិងរាំរែកនោះបានបន្លឺវាចារថា ៖

-ពួកយើងបានឡើងរាំជាង ៥បទម្ដាក់ហើយ នៅឡើយតែម៉ូដែលយប់នេះមិនទាន់បានឡើងរាំសោះ គេមានទឹកមុខគ្រៀមខ្លាំងណាស់តើមានវិបត្តិអ្វីទៅហ្ន៎ ? អូ ! ប្រហែលចាត់សង្សារមិនឃើញមកតាមពាក្យសន្យាហើយមើលទៅ !បើដូច្នេះពួកយើងត្រូវជួយស្វែងរកសង្សារម៉ូដែលផង !។

នាយតឿងើបឈរឡើងលើកដៃធានាខ្លួនថា ៖

-ខ្ញុំ ! សុំធានាឡើងឆាកច្រៀង ១បទដើម្បីហៅសង្សារម៉ូដែលអោយមកកាន់ទីនេះភ្លាម !

នាយតឿពោលហើយ ក៏ក្រោកដើរទៅកាន់កន្លែងច្រៀងដោយឱ្យប្រាប់សេហ្វអ័រកេសអោយលេងបទ ចាត់អូន...ភ្លេងក៏ចាប់លេងបទចាត់អូន...។



សម្លេងរបស់អាតឿតំរូញឡើងគ្រលួចលន្លង់លន្លោចដូចជាវាកំពុងចាត់អូនមែនទែនធ្វើអោយម៉ូដែលមិនអាចអង្គុយស្ងៀមបានក៏ងើបដើរចេញពីតុ ។ចំណែកម៉ូដែនផតវីវរវល់និងអ្នកណាទៀយ ព្រោះគេជាប់ដៃជាមួយនាងកញ្ញាឡង់សេម្នាក់ប៉ីស្រស់ផូរផង់ ។

ម៉ូដែលដើរទៅជិតតុនាងធា ហើយឈរប្លែកជញ្ជាំងសម្លឹងមុខនាងរួចលើកកែវ



ស្រាបៀរអកបង្ហើយអស់ពីកែវ ។

នាងធាងាកមុខមកមើលយុវបុរសកំពុងលង់សមុទ្ទស្នេហ៍នេះក្នុងក្រសែភ្នែកពោរពេញដោយឥទ្ធិពលមន្តស្នេហ៍ព្រះនាងកាមទេព ។ ភ្នែកស្រស់ស្រីបាញ់ចំភក្ត្រាដ៏កំសត់របស់នាយបណ្តាលអោយរាងកាយនាយកម្លោះក្លាយជាទន់ភ្លន់អង្គុយចុះក្បែរនាង ។

_អាធា !បងចាំអូនយូហើយ !បងមកទីនេះក៏ព្រោះតែអូនម្នាក់ប៉ុណ្ណោះ !ហេតុ

អីបានជាអូនមិនទៅកំដរបង ?( ម៉ូដែលនិយាយទៅកាន់នាងធា)។

_បងកុំចាំខ្ញុំអី ! នៅទីនេះមាននារីស្អាតៗគគោគម៉េចក៏បងមិនទៅរកគេទៅ ?

_បងមិនអាចធ្វើដូច្នេះទៅកើតទេ !បងមើលមិនឃើញនារីណាផ្សេងទៀតដែលបងគាប់ចិត្តដូចអូនទេអូនដឹងចិត្តបងស្រាប់ហើយ បងបានចំណាយលុយកាក់មាសប្រាក់ច្រើនណាស់ដើម្បីអូន បងគ្មានស្ដាយស្រណោះទេអោយតែបានអូនមកកំដរបង ។

_បងដែល !ពាក្យបងនិយាយជាពាក្យពិតឬ?ខ្ញុំមិនមែនជាអ្នកបំផ្លាញបងទេឬ? ម៉ូដែលញញឹមងក់ក្បាល ហើយទាញដៃនារីមកអង្អែលថ្នមៗហើយពោលថា ៖

_អាធា ! បងមិនដែលចាត់ទុកអូនជាអ្នកបំផ្លាញបងទេ !បងមិនចង់ឃើញអូនមុខស្រពោនដាក់បងទេ ! អូនមានបញ្ហាអ្វីប្រាប់បងមកចុះណា៎ !

កញ្ញាធាយល់ចំណុចខ្សោយរបស់អ្នកកម្លោះហើយ ក៏ធ្វើជាជ្រួញចិញ្ចើមហើយពោលថា ៖

_អូនត្រូវការប្រាក់ ២០០ដុល្លាល្ងាចនេះសំរាប់អោយឪពុកអូនបង់ថ្លៃពេទ្យ អូនមិនដឹងទៅរកឯណាទេបងអូនព្រួយចិត្តណាស់ ។

_មិនអីទេអូនប្រាក់ប៉ុណ្ណឹងបងមានតើ ! នេះនែ៎ប្រាក់២០០ដុល្លាអូនយកទៅចុះ ( ម៉ូដែលពោលហើយហូតយកប្រាក់ពីហោប៉ៅក្រដាស់ ១០០ដុល្លា ២សន្លឹកដាក់ក្នុងដៃស្រស់ស្រី ។

អាធាញញឹមរីកមុខចិញ្ចាច សំពះអរគុណម៉ូដែលអ្នកកម្លោះយកដៃក្បៀកស្មានារីអោមយង់បណ្ដើរគ្នាឡើងរាំ ។ នាយតៀដែលទើបច្រៀងបទចាត់អូនចប់ ក៏ម្ចីម្នាទៅអញ្ជើញនាយខ្មៅឡើងច្រៀងបទ"ជួបអូន" វិញម្ដង ។

នាយខ្មៅដែលត្រូវប៉ុន្មានជើងពីល្ងាច និងជោគផ្ញើមជោគប្រមាត់ដោយស្រាបៀផង រាងទន់ខ្លាំងណាស់ខំត្រដរឡើងវេទិការច្រៀងទាំងទ្រេតទ្រោត ។ បទជួបអូន

របស់អាខ្មៅធ្វើអោយបរិយាកាសទីនោះ ដែលស្រងូតស្រងាត់លន្លង់លន្លោចប្រែក្លាយជាពុះកញ្ជ្រោលឡើងហ្វូងអ្នករាំទាំងស្រីទាំងប្រុស មើលទៅដូចស្ទួនបុប្ផត្រូវជំនោរបោកបក់ ។ នាយរាម និងម៉ូដែនដែលចូលចិត្តបទញាក់នោះ ត្រូវបាននារីពីរនាក់ទាញអោយឡើងរាំ ។ ពេលគេហត់គេនាំគ្នាទៅសំរាករួចពីបាត់ហត់បន្តិចគេរាំទៀតគេពុំបានគិតពីពេលវេលាកន្លងទៅនោះទេ ។

យប់កាន់តែជ្រៅហើយ ភ្ញៀវទាំងឡាយចាប់ផ្ដើមល្វើយអស់កំលាំង . ក្នុងភោជនីយដ្ឋានទិដ្ឋភាពអារាត់អារាយ ពាសពេញដោយសំបកកំប៉ុងប៊ីយ៉ែ ក្រដាសជូតមាត់ផ្សែងបារីអ្វូរអ៊ាប់ក្លិនស្រានិងក្លិនទឹកអប់ច្របូកច្របល់ និងសម្លេងរជីវវាយរបស់ភ្ញៀវដែលស្រវឹងងើបពីតុមិនចង់រួច ។ ភ្លេងលេងបទសាយណ្ណារា ភ្ញៀវចាកចេញពីក្នុងភោជនីយដ្ឋានហើយ នៅឡើយតែក្នុងបន្ទប់កញ្ចក់ខ្មៅឯណោះ គេឃើញម៉ូដែលនិងម៉ូដែនពីរនាក់បងប្អូនក្រាបដេកលក់នៅលើតុ មាត់បែកពពុះស្អុលធំក្លិនស្រាឆ្អួលពេញ បន្ទប់ ។

នាយរាមពោលទៅកាន់នាងកញ្ញាធាថា ៖

_ល្អណាស់ ! អាធា ! ឯងបានធ្វើការបានល្អណាស់ ! ប៉ុន្តែឯណាប្រាក់ ២០០ដុល្លាដែលម៉ូដែលអោយនាងត្រូវប្រគល់អោយយើងភ្លាម !

នាងធាធ្វើអេះអុញអោបកាបូបនាងជាប់ នាយរាមកញ្ឆក់កាបូបពីដៃនាងធាហើយហូតយកប្រាក់ ២០០ដុល្លាចេញមករួចដកយកលុយពីហោប៉ៅខ្លួនចំនួន ១០ដុល្លាដាក់អោយនាងវិញ ហើយពោលថា ៖

_នាងឯងមិនអាចទុកប្រាក់នេះទាំងអស់បានទេ ! ប្រាក់នេះជារបស់យើងបានដោយសារគំនិតនិងកលល្បិចរបស់យើង !យើងអោយនាង ១០ដុល្លាវាច្រើនពេកផង !

នាងធាធ្វើមុខស្ញើរួចពោលទៅកាន់នាយរាមថា ៖

-ប្រាក់នេះបងម៉ូដែលអោយខ្ញុំទេតើ ! រឿងរបស់លោកទាក់ទងតែរឿងកាំភ្លើង·



នោះប៉ុណ្ណោះ ព្រោះលោកបានអោយខ្ញុំធ្វើកលល្បិចដាក់ថ្នាំសណ្តំដើម្បីយកកាំភ្លើងពីបងម៉ូដែលវិញ ឥឡូវខ្ញុំបំពេញភារកិច្ចជូនលោករួចហើយសូមលោកអោយប្រាក់២០០ដុល្លានេះមកខ្ញុំវិញមក ប្រាក់នេះជារបស់ខ្ញុំទេលោក !។

នាយរាមលឺនាងពោលដូច្នេះ ក៏ក្តៅឆេវឡើងហើយពោលទាំងសង្រ្កិតធ្មេញដាក់នាងកញ្ញដ៏ស្រស់ប្រិមប្រិយថា ៖

-នាងល្អ !កុំអាលភ្លេចខ្លួនពេក !ត្រូវដឹងថានាងជាអ្នកណា មកពីណា ! ហើយត្រូវទៅណា ! បើកុំបានក្បាលខ្ញុំជួយនាងពីកណ្តាប់ដៃអាចោរបោកមនុស្សយកមកលក់នោះ ស្មានថារូបនាងបានមកឈរទីនេះ ស្លៀកពាក់ល្អស្អាតដូច្នេះសុខស្រួលដូច្នេះឬ ? នាងកុំស្មានខ្លួននាងជានារីមានសេរីភាពដូចគេអោយសោះ !គិតបន្តិចទៅមើលស្រីល្អ ! ពេលនេះនាងនៅក្នុងកណ្តាប់ដៃខ្ញុំហើយត្រូវតែធ្វើអ្វីតាមបញ្ជាខ្ញុំ បើមិនដូច្នោះទេកុំថាពួកខ្ញុំកាចណាំ !



អាតៀដែលឈរក្បែរនោះយកដៃច្បួតសក់នាងធា.ឯអាខ្មៅយកដៃបិចថ្ពាល់នាងហើយសើចហះៗ ។ នាងធាទះដៃអាខ្មៅចេញ និងច្រានវាថ្មប់ជញ្ជាំងនាងពោលទៅកាន់នាយរាមថា ៖

-លោក ! ខ្ញុំសុំអង្វរលោកសូមលោកអោយខ្ញុំត្រឡប់ទៅស្រុកកំណើតខ្ញុំវិញទៅខ្ញុំនឹកម្តាយខ្ញុំណាស់ខ្ញុំបានបំរើលោកយូរថ្ងៃហើយ !ខ្ញុំមិនភ្លេចគុណលោកទេដែលលោកបានជួយខ្ញុំអោយរួចពីកណ្តាប់ដៃពួកបោកមនុស្សយកមកលក់នោះ ។ ខ្ញុំមិនអាចប្រព្រឹត្តអំពើមិនគប្បីចំពោះបងម៉ូដែលតទៅទៀតទេ ខ្ញុំអាណិតគាត់ណាស់ដែលខ្ញុំបានបោកប្រាស់គាត់តាមបញ្ជារបស់លោក !

លឺពាក្យអង្វរបស់នាងដូច្នេះនាយរាមសើចហើយពោលថា ៖

-នាងអាណិតអាម៉ូដែលហ្នឹងឬ ? នាងត្រូវដឹងថាវាជាកូនគហបតីវាមានលុយអាចទិញនារីល្អៗដូចនាងសំរាប់បំរើសេចក្តីសប្បាយរបស់វា វាគ្មានបេះដូងសំរាប់នាងទេ ហើយពិសេសទៅទៀតនោះ បើអាម៉ូដែលនេះវាដឹងថានាងបានបោកប្រាសវាផងនោះ វាមុខជាទាត់នាងចោលបាត់ទៅហើយ !

-រឿងគាត់ស្រឡាញ់ខ្ញុំឬមិនស្រឡាញ់ ឬបោះបង់ខ្ញុំចោលមិនសំខាន់ទេ តែនាងខ្ញុំមិនចង់បោកប្រាសគាត់តទៅទៀត !

ពេលនោះអាខ្មៅដែល អម្បាញ់មិញត្រូវនាងធាច្រានទៅគៀនជញ្ជាំងនោះបានស្ទុះមកចាប់ច្បាមសក់នាងធាតែត្រូវនាយរាមឃាត់ថា ៖

-បានហើយ ! កុំធ្វើផ្តេសផ្តាស់នៅទីនេះ !អាខ្មៅអាតៀចាត់ការយកអាពីរនាក់ដាក់ឡានទៅវីឡាទួលគោកវិញ ។

រំពេចនោះថៅកែរង្គសាលរាងធាត់កន្ត្រៀបានដើរចូលមក នាយរាមអោនខ្សិប

ទៅថៅកែថា ៖

-យប់នេះខ្ញុំយកអាផាទៅជាមួយដើម្បីអោយជួយមើលអាម៉ូដែលនិងអាម៉ូដែន !

ថៅកែចិននោះឆ្លើយថា ៖

-អូខេ ! ស្រេចតែលោកទេ ខ្ញុំប្រគល់នាងជូនលោកវិញហើយបាទ ។

ក្រោយពីបានគិតគូរថ្លៃស៊ីធីករួចរាល់ហើយអាខ្មៅអាតឿ និងនាងផាបានលើកម៉ូដែល និងម៉ូដែនដាក់ឡាន ហើយនាយរាមក៏ឡើងបើកសំដៅទៅវីឡាទួលគោក ។

ឃើញពន្លឺហ្វាឡានបញ្ចាំងមកចំ . ពូក្លឹងស្ទុះទៅបើកទ្វាររបង . រថយន្តក៏ចូលចតក្នុងរោងដាក់ឡាន ពូក្លឹងប្រញាប់បិតរនាំងទ្វារដែកវិញជាបន្ទាន់ ។នាយរាមបញ្ជាអោយពូក្លឹងលើកម៉ូដែល និងម៉ូដែនទៅដាក់ក្នុងបន្ទប់ជិតរោងឡានហើយបញ្ជាអោយពូក្លឹងឃាមកាមមិនអោយអ្នកណាចូលមកជិតឡើយ ។

នាងម៉ាប់ដែលកំពុងដេកលក់នៅបន្ទប់ជិតនោះ ភ្ញាក់សើងមម៉ើងឡើងដោយលឺស្នូរដើរព្រុះព្រះក៏ចូលមកអើតមើល ឃើញម៉ូដែលនិងម៉ូដែនដេកស្ដូកត្រូវគេសែងទៅដាក់នៅលើគ្រែដូច្នេះក៏ស្រែកយ៉ៃ ។

-ពុទ្ធោ ! ងាប់ឬរស់លោកអើយ ?

នាយរាមគំរាមនាងម៉ាប់ថា ៖

-មីងម៉ាប់មាត់ចង្រៃនេះថយចេញទៅ !

នាងម៉ាប់ត្រូវនាយរាមដេញ ក៏ស្ទុះចេញពីបន្ទប់នោះមកក្រោវិសជាន់ពូជិមដែលពួនលួចមើលនៅក្បែរនោះ នាងម៉ាប់ភ្ញាក់ស្រែកយ៉ៃស្មានថាខ្មោចលង ព្រោះឃើញពូជិមមុខចម្លែក ( នាងម៉ាប់មិនបានដឹងថាពូជិមមកស្នាក់នៅជាមួយពូក្លឹងទេ ) ពូជិមប្រញាប់សំពះអង្វរនាងម៉ាប់កុំអោយមាត់ ។ នាងម៉ាប់ក៏សួរពូជិមតិចៗថា ៖

-ពូឯងមកពីណា ?

-ខ្ញុំមកតាមរកក្មួយខ្ញុំពីរនាក់នេះ !(ពូជិមតបវិញ)

នាងម៉ាប់នៅស្ងៀមងក់ក្បាលយល់សាច់រឿង ។ ពូជិមនិងនាងម៉ាប់លួចមើលតាមប្រហោងបង្អួចទៅក្នុងបន្ទប់ឃើញនាយរាមកំពុងចាត់ចែង

-យើងចាំបាច់ត្រូវដាក់ថ្នាំសណ្ដំវាដូច្នេះ ដើម្បីយកកាំភ្លើងពីវា(នាយរាមមាត់និយាយដៃកាន់កាំភ្លើងផ្ទៀងផ្ទងពិនិត្យមើល រួចហុចកាំភ្លើងនេះទៅអោយអាខ្មៅ ) កាំភ្លើងនេះអោយអាខ្មៅអ្នកកាន់ប្រើប្រាស់ក្នុងពេលបំពេញកិច្ចការពិសេសរបស់យើងនៅថ្ងៃស្អែក ។

អាខ្មៅទទួលកាំភ្លើងសៀតទុកនៅចង្កេះខោវា នាយរាមបន្តសំដីទៀតថា ៖

-ព្រឹកស្អែកពូក្លឹងអាតឿអាខ្មៅត្រូវចេញដំណើរពីងងឹត ដោយក្លែងខ្លួនជាអ្នកដំណើរធម្មតាឆ្ពោះទៅកំពង់ស្ពឺ ដើម្បីទៅជួបពួកក្មួយប្អូនប្រុសពូក្លឹង ។ ពួកយនិងចាត់ចែងនាំពួកឯងទៅជីកកំណប់មាសនោះ ។ ឯកាំភ្លើង ១ដើមនេះទុកការពារពេលជីកកំណប់បានលឺទេ ?

_បាទ !

_បាទ !

_បាទ !

អ្នកទាំងបីឆ្លើយព្រមគ្នាទទួលបញ្ជាពីនាយរាម . នាយរាមបន្តវាចាថា ៖

_ចំណែកខ្ញុំ មិនបានទៅជីកកំណប់ទេ ព្រោះខ្ញុំជាប់រវល់ទៅទទួលពូខ្ញុំមកពីស្រុកបារាំង ហើយម្យ៉ាងទៀតខ្ញុំចាត់ចែងរឿងអាពីរនាក់នេះផង ។

ពូក្លឹងផ្អៀតសួរនាយរាមថា ៖

_លោកក្មួយ ចុះចំណែកម៉ូដែលនិងម៉ូដែន ?

- រឿងពួកវាពីរនាក់នេះមិនអីទេ ! ព្រឹកស្អែកវាដឹងខ្លួនវិញហើយព្រោះថ្នាំសណ្ដំនេះវាខ្សោយទេ មានរយៈពេលតែ៦ម៉ោងប៉ុណ្ណោះ ។ ព្រឹកស្អែកយើងបញ្ជូនពួកវាទៅអោយម៉ែឪវាវិញ លឺថាស្អែកឪវាត្រឡប់មកពីសំពួរផង បើយើងទុកវានៅទីនេះនាំមានបញ្ហាមិនខាន ។

ពូភ្លឹងស្រាប់តែនឹកឃើញរឿងអ្វីម្យ៉ាង ក៏ពោលទៅកាន់នាយរាមថា ៖

- លោកក្មួយ ! ខ្ញុំភ្លេចជំរាបលោកក្មួយ កាលពីក្បាលព្រលប់ដែលលោកក្មួយនាំគ្នាចេញទៅរាំនៅបារនោះ មានបុរសពីរនាក់ត្រូវជាមារបស់ក្មួយម៉ូដែលនិងម៉ូដែនបានមកដល់ទីនេះសួររកក្មួយទាំងពីរនេះហើយក៏មានលោកបងម្នាក់មកជាមួយដែរតែឡានចេញចោលគាត់បាត់ទៅ លោកបងនោះក៏សុំសំណាក់នៅទីនេះដែរ !។

នាយរាមបើកភ្នែកធំៗហើយសួរថា ៖

- មានរឿងអីចឹងផង ? តើពូនោះដេកនៅទីណា ?

ពូភ្លឹងតបថា ៖

- នៅក្នុងផ្ទះខ្ញុំឯណោះ !

ពេលនោះពូជិមដែលលួចស្ដាប់ដឹងថាគេនិយាយចំណើខ្លួនគាត់ ហើយនាយរាមបំរុងរកមុខគាត់ក៏រត់ម្នីម្នាចូលក្នុងផ្ទះពូភ្លឹងវិញយ៉ាងរហ័ស ឡើងលើគ្រែគ្រលំក្រម៉ាធ្វើដេកស្រមុកខុលៗ ។ ពូភ្លឹងនាំនាយរាម អាតឿ អាខ្មៅចូលទៅមើលក្នុងផ្ទះឃើញពូជិមដេកស្រមុកខុលៗក៏គ្មាននឹកសង្ស័យអ្វីឡើយ នាំគ្នាត្រឡប់ទៅវិញអស់ទៅ ។

នាយរាមដើរត្រឡប់ចូលបន្ទប់ដែលដាក់អ្នកសន្លប់ទាំងពីរវិញ ហើយបង្ខំនាងធាអោយស្ថិតនៅជាមួយអ្នករងគ្រោះទាំងពីរក្នុងបន្ទប់នោះ រួចហើយក៏ចេញមកក្រៅចាក់សោរបន្ទប់នោះយ៉ាងមាំ ។

នាយរាមដោយហេវហត់អស់កម្លាំងពេក ឡើងទៅសំរាកនៅបន្ទប់ខាងលើបាត់





ទៅ ។ ឯពួកអាខ្មៅ អាតឿ ពូភ្លឹងក៏បែកគ្នាទៅរកដេកពួនរៀងៗខ្លួនដែរ ។

ឃើញស្ងាត់មនុស្សអស់ហើយ នាងម៉ាប់ដើរលបៗមកអើតមើលក្នុងបន្ទប់ដែលឃុំខ្លួនម៉ូដែល និងម៉ូដែន ។ដោយចៃដន្យនាងម៉ាប់មានកូនសោរបន្ទប់នោះមួយដែរព្រោះនាងម៉ាប់ជាអ្នកបោសសំអាតបន្ទប់ទាំងអស់ក្នុងផ្ទះ ។នាងម៉ាប់ចាក់សោរបន្ទប់ចូលទៅឃើញនាងធាអង្គុយកំព្រោននៗនៅគៀនជញ្ជាំងនាងកុំពុងភ័យញ័រខ្លួន ខ្លាចអ្នករងគ្រោះទាំងពីរដែលសន្លប់ស្ដូកស្ដឹងដូចខ្មោចតែហោង ។ នាងម៉ាប់ធ្វើសញ្ញាមិនអោយនាងធាមាត់ឡើយ ។ នាងស្ទុះទៅយកកន្សែងជ្រលក់ទឹកក្ដៅអ៊ុនៗពីផ្ទះបាយមកជូតខ្លួនអោយយុវជនទាំងពីរ ដែលមានខ្លួនទន់ល្វើយនៅសល់តែដង្ហើមតិចៗ ។ នារីទាំងពីរខំប្រឹងជួយដោះអាវអ្នកសន្លប់ និងខំប្រឹងជួយធ្វើអោយភ្ញាក់ តែអ្នកទាំងពីរនៅតែសន្លប់ដដែល ។ ពេលកំពុងជូតខ្លួនអោយនាយម៉ូដែន ស្រាប់តែកូនកញ្ចប់ក្រណាត់តូចមួយធ្លាក់ចេញពីចង្កេះខោម៉ូដែន នាងធានិងនាងម៉ាប់រើសកញ្ចប់នោះមកលាមើលឃើញចិញ្ចៀនពេជ្រ

បន្ទោងពេជ្រ និងត្បូងមានតម្លៃភ្លឺផ្លេកៗ នាងម៉ាប់ក៏ពោលទៅកាន់នាងធាថា ៖

_របស់នេះមានតំម្លៃខ្លាំងណាស់ បើពួកបីសាចទាំងនោះឃើញមុខជាវាឆក់ប្លន់យកអស់ហើយ ដូច្នេះយើងត្រូវលាក់ទុកអោយគ្នាផង ចាំដល់ក្លយម៉ូដែលម៉ូដែនភ្ញាក់ឡើងយើងប្រគល់អោយគេវិញ។នាងធាងក់ក្បាលយល់ព្រមហើយក៏ប្រគល់កញ្ចប់នោះអោយនាងម៉ាប់ជាអ្នកទុក ។

នាងម៉ាប់សម្លឹងនាងធាដោយក្តីអាណិតអាសូរ ក្រោយពីរសួរនាំដឹងថានាងធាត្រូវគេបោកប្រាសយកមកលក់ដូច្នេះ នាងម៉ាប់គិតរកមធ្យោបាយជួយនាងធា ។ ពេលនោះនាងម៉ាប់នឹកឃើញមធ្យោបាយមួយ ក៏ដើរលបៗទៅអើតមើលផ្ទះពូភ្លឹង រកមើលពូជិមដេកនៅក្រៃក្រៅផ្ទះនោះ ។

ពូជិមដេកមិនលក់ទេ គាត់គ្រាន់តែសំងំចាំតាមដានមើលហេតុការណ៍តទៅទៀត ។ គាត់ឃើញច្បាស់ជានាងម៉ាប់ដើរមក ពូជិមក៏ងើបលបៗទៅជួបនាងម៉ាប់ នាងម៉ាប់និយាយខ្សឹបៗដាក់ត្រចៀកពូជិម អោយពូជិមជួយនាំនាងធារត់ផង ហើយនាងម៉ាប់ធានាទៅចាក់សោរទ្វាររបងខាងក្រោយអោយ ។

ពូជិមទទួលយល់ព្រមហើយដើរលបៗចេញទៅឈរចាំជិតទ្វាររបងខាងក្រោយវិទ្យា ។នាងម៉ាប់មកនាំនាងធាខ្សឹបប្រាប់ថាអោយទៅតាមពូជិមទៅ ពូជិមនិងនាំនាងរត់ទៅសំណាក់នៅផ្ទះគាត់សិន......។

នាងធាភ័យណាស់ ព្រោះនាងមិនដែលស្គាល់ពូជិមសោះនាងខ្លាចពូជិម.....តែពូជិមលើកដៃសំពះទៅលើថាគាត់សុំស្បថគាត់មិនមែនមនុស្សអាក្រក់ទេ ។ គាត់ពិតជាមានបំណងជួយក្មួយស្រីគាត់នេះពិតមែន ។

ពេលនោះនាងធាឈរស្ងៀមបន្តិច បង្ហូរទឹកភ្នែក......នាងងាកមុខមកសម្លឹង



មើលបន្ទប់ដែលម៉ូដែលកំពុងដេកសន្លប់ស្តូកស្តឹង ។ ពេលនេះទើបនាងដឹងថា នៅក្នុងបេះដូងនាងមានស្នាមនៃក្តីអាឡោះអាល័យមួយជិតជាប់នៅក្នុងនោះ តែពេលនេះនាងមិនដឹង ជ្រើសរើសវិធីណាទៀតឡើយក្រៅពីរំដោះខ្លួនចេញពីឋាននរកនេះ ។

បុរសចំណាស់ និងយុវតីខំប្រឹងដើរផងរត់ផងទាំងយប់ងងឹត ឆ្ពោះទៅលំនៅរបស់ពូជិមឯពេទ្យលោកសង្ឃ ។ ដើរអស់រយៈពេល ១ម៉ោងប្លាយពូជិមបានទៅដល់ផ្ទះគាត់ គាត់គោះទ្វារហៅមីងសៅ.....

_ម៉ែវ៉ា បើទ្វារ......!

មីងសៅភ្ញាក់ពីដំណេកដោយលឺសម្លេងពូជិម គាត់បើកទ្វារផ្ទះឃើញពូជិមនិងនាងធា មីងសៅនឹកឆ្ងល់ថាពូជិមទៅណាចាត់ ១យប់មកវិញមានស្រីម្នាក់ស្អាតភ្លឹងមកជាមួយ គាត់ឆ្ងល់ឈរភាំងនិយាយមិនចេញ ។

ពូជិមហៅនាងធាអោយប្រញាប់ចូលក្នុងផ្ទះ ហើយនិយាយរឿងសព្វគ្រប់ប្រាប់ប្រពន្ធគាត់ ។ មីងសៅក៏អាណិតនាងធាខ្លាចចិត្ត ហើយរៀបចំកន្លែងអោយនាងធាសំរាក ។

ពីរនាក់ពូ និងមីងគិតថាស្អែកឡើង និងជួយរកមធ្យោបាយអោយនាងធាបានត្រឡប់ទៅស្រុកវិញ ។

.............................

ម៉ោង ៦ព្រឹកម៉េងបើកឡានមកហៅសាវ៉ាន់ និងកម្មករប្រុសៗពីរនាក់អោយជូនទៅវិទ្យានាយរាមឯទួលគោក ។ សាវ៉ាន់ដែលស្លៀកពាក់រួចស្រេចរៀបចេញដំណើទៅជាមួយម៉េងក៏ស្រាប់តែឃើញពូជិមរត់មកឃាត់

_ឈប់សិន ! កុំទាន់ទៅណាំ ! និយាយគ្នាសិនឹងឯងពីរនាក់នេះម៉េចបើកឡាន

ចោលយើងកណ្តាលយប់នៅទួលគោកហ្នឹះ ?

-ពួឯងចុះពីលើឡានពេលណាខ្ញុំអត់ដឹង ?(ម៉េងតបទៅពូជិមវិញ)

-ពេលឯងឈប់ឡាននៅវិឡាទួលគោកនុះណាំ ឆ្នាឈើពោះបត់ជើងក៏ចុះពីលើឡាន ឯងបែរជាបើកឡានល្បឿនរុយចោលខ្ញុំទៅបាត់ ខ្ញុំហៅអត់លឺ

-អូហូ ! អីចឹងទេហ្អី !(ម៉េងអស់សំណើច)

-អាហ្នឹងហើយដែលពួឯងថាផឹកមិនអោយគេសែងនោះ !បើឡានចេញចោលហើយពូដើរមកផ្ទះខ្លួនឯងអីចឹងបានហៅថាអ្នកជើងឯកផឹកស្រាមែនទេ ?

សាវ៉ាន់លេងសើចជាមួយពូជិមពូជិមចង្អុលមុខសាវ៉ាន់ហើយពោលតបវិញថា៖

-យី ! អាក្មួនក្មេងអត់បានការអី ! ដឹងយប់មិញនេះមានរឿងអីខ្លះកើតឡើងទេ ? ឯងទាំងពីរនាក់មកដេកផ្ទះបាត់ ឯខ្ញុំមិនចោលម្សៀតដូចពួកឯងទេ ! ខ្ញុំដេកនៅវិឡាទួលគោកនោះតែម្តង ចាំមើលហេតុការណ៍តទៅទៀត (ពូជិមបាននិយាយរ៉ាយរ៉ាប់រឿងរ៉ាវសព្វគ្រប់អោយនាយម៉េងនិងសាវ៉ាន់ស្តាប់)។អ្នកទាំងពីរក៏បែរជាសុំទោសពូជិមនិងសរសើរគាត់ដែលបានបំពេញអំពើកុសលមួយបានលទ្ធផលល្អប្រសើរណាស់ ។ ប៉ុន្តែពេលវេលាខ្លីណាស់ មិនអាចអោយនាយម៉េង និងសាវ៉ាន់បានជួបយកពត៌មានពីនាងធាទេ ព្រោះនាងអស់កម្លាំងសំរាកមិនទាន់ក្រោកនៅឡើយ ។

ពួកគេក៏បបួលគ្នាទាំងពូជិមផងឡើងឡានសំដៅទៅវិឡានាយរាមឯទួលគោកតែម្តង ។ ពេលពួកគេមកដល់វិឡានោះ គេឃើញទ្វាររបងភូមិគ្រិះចាក់សោរជាប់ពីក្នុងហើយមានសភាពស្ងាត់ជ្រងំ ។

ពូជិម និងម៉េងស្រែកហៅ និងអង្រន់សោរមួយសន្ទុះទើបឃើញមីងម៉ាប់ដើរមក ។ នាងម៉ាប់ស្គាល់ពូជិមក៏ប្រញាប់បើកទ្វារ ពូជិមសួរនាងម៉ាប់ថា ៖

-ពួកគេទាំងពីរនាក់ដែលសន្លប់នោះភ្ញាក់ដឹងខ្លួនហើយឬនៅ ?

នាងម៉ាប់ឆ្លើយតិចៗថា ៖

-ស៊ូត ! កុំមាត់លឺពេក ! ពួកគេដឹងខ្លួនតិចៗហើយតែខ្ញុំមិនដឹងថាពួកគេពីរនាក់នោះយ៉ាងណាទៅហើយទេ ព្រោះខ្ញុំមិនហ៊ានទៅជិតបន្ទប់នោះ !

-ហេតុអី ?(នាយម៉េងសួរ)

-ខ្ញុំខ្លាចអ្នកប្រុសរាមឃើញវិវរឥឡូវហើយ !

-អាគាត់រាមហ្នឹងវាជាស្អី ? បីសាចឬ ?ក៏ខ្លាចវាម្ល៉េះ ?(សាវ៉ាន់ឧទានឡើង)

-លោកអើយកុំមាត់លឺពេក ! ខ្ញុំព្រឺខ្លួនខ្លាកៗទៅហើយ ! ខ្ញុំខ្លាចអ្នកប្រុសរាមណាស់ គាត់កាចសម្បើមណាស់ ត្រូវវ៉ាយៗភ្លាមត្រូវចាក់ៗខ្ញុំខ្លាច....ហឺ !!ៗៗ ។

នាងម៉ាប់ពោលមិនទាន់ផុតមាត់ផង សម្លេងមួយបន្លឺឡើង ៖

-អរុណសួស្តី អស់លោក ! អញ្ជើញមកមានការអីនៅក្នុងផ្ទះខ្ញុំទាំងព្រឹកម្ល៉េះ?

(សម្លេងនាយរាមឈរយ៉ាងសង្ហារនៅលើរានហាលខាងមុខភូមិគ្រិះ .គេស្លៀកពាក់ខ្មៅពាក់មួកខ្មៅមើលទៅដូចជាបីសាចគួរព្រឺក្បាល ) នាយម៉េងនាំបក្សពួកដើរទៅឈរជិតជណ្តើរភូមិគ្រិះសម្លឹងមើលទៅលើ ហើយពោលថា ៖

-ពួកយើងមករកក្មួយម៉ូដែលនិងម៉ូដែន ! យើងត្រូវការជួបពួកគេហើយនាំគេត្រឡប់ទៅផ្ទះវិញ !

-តើពួកលោកត្រូវជាអ្វីនិងគេ ?

-ពួកយើងត្រូវជាមានិងជាមិត្តភក្តិរបស់ម៉ូដែលម៉ូដែន !លោកឯងមិនបាច់ធ្វើជាមិនស្គាល់ពួកយើងនោះទេ ! តាមពិតយើងបានស្គាល់គ្នាច្បាស់លាស់កាលពីម្សិលមិញនៅត្បៀនស្វាយ ! ខ្ញុំបានប្រយុទ្ធជាមួយលោកឯងផ្ទាល់ ហើយត្រូវអាខ្មៅក្មួរបស់



លោកឯងចាញ់ខ្ញុំពីនាក់ត្រូវរបួសជើងដៃផង។តែយើងមកនេះមិនមែនមករករឿងលោកឯងរឿងចាញ់យើងម្សិលមិញនោះទេ ។ យើងមកនាំគ្នាយើងត្រឡប់ទៅផ្ទះវិញប៉ុណ្ណោះ !

-បាន ! ខ្ញុំយល់ !ប្រសើរណាស់ដែលពួកលោកមិនបង្ករឿងជាមួយខ្ញុំ ! ឥឡូវសូមអញ្ជើញមកតាមខ្ញុំ !

ពោលរួច នាយរាមដើរចុះមកក្រោមនាំមុខក្រុមនាយម៉េងសំដៅបន្ទប់ដែលដាក់ម៉ូដែលនិងម៉ូដែន ។ ពេលបើកទ្វារបន្ទប់ឡើង ទាំងអស់គ្នាឃើញយុវជនទាំងពីរដេករដីរវាយព្រោះទើបភ្ញាក់ដឹងខ្លួនពីថ្នាំសណ្តំ ។

ចំណែកនាយរាមខំប្រឹងសម្លឹងរកមើលនាងធា មិនឃើញនៅក្នុងបន្ទប់នោះក៏



បើកភ្នែកធំសំឡក់យ៉ាងសាហាវទៅរកនាងម៉ាប់ ។ ម៉ាប់ភ័យស្ទើរលោះព្រលឹងអោនមុខចុះ ។

នាយម៉េង នាយសាវ៉ាន់និងកម្មករពីរនាក់ក៏ប្រញាប់ប្រញាល់ទៅលើកបីម៉ូដែលម៉ូដែនចេញពីបន្ទប់នោះ ។

នាយរាមឈរយ៉ាងសង្ហារពោលឡើងថា ៖

-អ្នកទាំងអស់គ្នាឃើញទេ ម៉ូដែលនិងម៉ូដែនពិតជាមានសុខភាពល្អណាស់ ! យប់មិញគេរាំយ៉ាងសប្បាយជាមួយសង្សារគេ គេផឹកស្រាបៀរច្រើនហួសពេករហូតដល់គេដេកលក់លែងដឹងខ្លួនតែម្តង ! ហះហះហាំសូមពួកលោកកុំបារម្ភអី !នេះជារឿងធម្មតារបស់ពួកយើងទេ !

តាជិមដែលឈរជិតនោះ លឺនាយរាមពោលដូច្នោះ គាត់អោនខ្សិបដាក់នាយម៉េងថា ៖

-អាបិសាចនេះវាកុហកទេ ! ខ្ញុំដឹងរឿងវាអស់ហើយ ! ខ្ញុំចង់តែលេងវាអោយរឹងដៃម្តង !

នាយម៉េងពោលឃាត់ពូជិមថា ៖

-កុំអីពូ ! យើងមិនអាចបង្កអោយមានបញ្ហានៅទីនេះបានទេ ព្រោះជាទឹកដីរបស់វា យើងត្រូវប្រញាប់ចាកចេញពីផ្ទះនេះអោយផុតសិន !

សាវ៉ាន់ពោលបន្តពីនាយម៉េងថា ៖

-ផ្ទះនេះធំណាស់ ហើយអារាមនេះវារស់នៅម្នាក់វាគួរអោយខ្លាចណាស់ ខ្ញុំមើលទៅដូចជាបីសាចជ្រាតូឡាក្នុងរឿងកុនបារាំងដូច្នោះ

-កុំនិយាយច្រើន ! ទៅប្រញាប់ចាកចេញពីទីនេះ ( ម៉េងតឿនអ្នកទាំងអស់គ្នា

អោយយកអ្នករបគ្រោះទៅរថយន្ត )

វំពេចនោះ នាងម៉ាប់រត់គេចចេញពីជ្រុងផ្ទះម្ខាងកាន់បង្វិចតូចមួយភ័យសង្កៀរ សស្លក់ហើយពោលអង្វរនាយម៉េងដោយសំពះផងយំផងថា ៖

_អស់លោកអាណិតមេត្តាជួយនាំខ្ញុំចេញពីទីនេះផង ! ខ្ញុំមានការណ៍សំងាត់សំខាន់ណាស់ចង់ជំរាបអស់លោក ខ្ញុំមិនអាចជំរាបអស់លោកនៅទីនេះបានទេ ! សូមអស់លោកនាំខ្ញុំទៅជាមួយផង ។

សម្ដេងនាយរាមស្រែកប្ញូចរន្ទះ

_មីងម៉ាប់ ! មកណេះ ! មីងម៉ាប់កុំទៅណា ! មីងម៉ាប់......មីងម៉ាប់.....មីងម៉ាប់.....(សម្ដេងនាយរាមរសាត់កាន់តែឆ្ងាយទៅ...ព្រោះរថយន្តនាយម៉េងបានចាកចេញពីវិទ្យាយកនាងម៉ាប់ទៅជាមួយឆ្ងាយណាស់ទៅហើយ....។

# វគ្គទី ៤



ម៉ូដែលបើកភ្នែកសន្សឹមៗសម្លឹងមើលមនុស្សជុំវិញខ្លួន អារម្មណ៍អ្នកកំពុងវិលវល់យ៉ាងខ្លាំង . សម្លេងដែលអ្នកលឺមុនគេបំផុតគឺសម្លេងម្ដាយរបស់អ្នក

_កូនដែល ! កូនលឺម្ដាយហៅទេ ? កូនដែល !

ម៉ូដែលខំបើកភ្នែកសម្លឹងម្ដាយ បន្តិចមកនាយបែជាស្រក់ទឹកភ្នែករលីងរលោងហើយពោលទាំងរជីវវាយ ស្រែកហៅឈ្មោះនារីម្នាក់.....

_អូនធា ! ឯណាអូនធា ?

អ្នកទាំងអស់គ្នាដែលនៅព័ទ្ធជុំវិញ សម្លឹងមើលមុខគ្នាទៅវិញទៅមក ។

អ្នកស្រីភោគាដែលអង្គុយនៅចន្លោះកូនប្រុសទាំងពីរ នឹកឆ្ងល់ថាតើកូនរបស់អ្នកស្រីស្រែកហៅឈ្មោះអ្នកណា ?មានតែពូជិមនិងនាងម៉ាប់ទេដែលយល់បានថាអ្នកប្រុសម៉ូដែលស្រែកហៅឈ្មោះអ្នកណា

ប៉ុន្តែពុំទាន់មានអ្នកណាម្នាក់ចាប់អារម្មណ៍បកស្រាយរឿងនេះទេ ព្រោះលោក

គ្រូពេទ្យកំពុងត្រួតពិនិត្យសុខភាព និងចាក់ថ្នាំបន្សាបជាតិថ្នាំសណ្តំអោយអ្នកកម្លោះទាំងពីរ ។

បន្តិចមក ម៉ូដែនជាប្អូនបានភ្ញាក់ដឹងខ្លួនវិញហើយ ។ នៅតែម៉ូដែលមិនទាន់បាត់រជើរវាយ ស្រែកហៅឈ្មោះនាងធាជាប់ជានិច្ច ។

ទ្រាំមិនបានអ្នកស្រីក៏សួរទៅម៉េង ៖

_ម៉េងហាំ កូនដែលស្រែកហៅឈ្មោះនាងធា តើនាងធាជាអ្នកណា ?

ម៉េងលីបងស្រីសួរដូច្នេះក៏បែមើលមុខនាងម៉ាប់ និងពូជិមដែលអង្គុយជិតនោះហាក់ដូចជាចង់អោយពូជិមឬនាងម៉ាប់ជំរាបអ្នកស្រីព្រោះរឿងនេះពុំអាចលាក់ចំពោះអ្នកស្រីបានតទៅទៀតទេ ។

អ្នកស្រីថយទៅអង្គុយលើសាឡុង រង់ចាំស្តាប់ការរៀបរាប់របស់នាងម៉ាប់និងពូជិម ។ ពូជិមជំរាបអ្នកស្រីតាមត្រង់តាមដំណើររឿងពិតរបស់នាងធា និងម៉ូដែល ។

អ្នកស្រីងកឃ្លើមធំ សម្លឹងមើលទៅកូនប្រុសដែលកំពុងរជើរវាយ អ្នកស្រីក៏សួរទៅពូជិម និងនាងម៉ាប់ថា ៖

_តាមពូនិងនាងយល់ តើនាងធានោះជានារីបែបណា ? ចរិយាមាយាទពិតប្រាកដរបស់នាងដូចម្តេច ?

នាងម៉ាប់ដែលអង្គុយបត់ជើងលើឥដ្ឋការូរលោងស្រិល បានតបទៅអ្នកស្រីវិញដោយកាយវិការគោរពថា ៖

_ជំរាបអ្នកស្រី...នាងធាពិតមែនតែនាងជានារីខ្វាត់ព្រាត់ ត្រូវគេបោកមកពីខេត្តឆ្ងាយមែន តែមានចរិតល្អប្រពៃណាស់ ។នាងគ្មានគំនិតអាក្រក់លោភលន់ចង់បានទ្រព្យសម្បត្តិឬមាសប្រាក់របស់អ្នកប្រុសម៉ូដែលទេ ។ ខ្ញុំមានរឿងពិតមួយចង់បញ្ជាក់ពីទឹកចិត្តល្អប្រពៃរបស់នាងធាជំរាបអ្នកស្រីពេលនេះ ។



ពោលដូច្នោះហើយនាងម៉ាប់ក៏លូកយកកញ្ចប់ក្រណាត់មួយដុំពីក្នុងហោប៉ៅអាវមកជូនអ្នកស្រី . អ្នកស្រីទទួលកញ្ចប់នោះមកលាមើល ក៏បើកភ្នែកធំលាន់មាត់ថា ៖

_នេះជាមាសប្រាក់ និងត្បូងពេជ្ររបស់ខ្ញុំទេតើ !

_ចាំ ពិតហើយអ្នកស្រី ! កញ្ចប់វត្ថុមានតំលៃនេះត្រូវបាននាងធារើសបានពេលអ្នកប្រុសម៉ូដែនសន្លប់ក្នុងបន្ទប់ ហេតុតែនាងជានារីសុចរិតទៀងត្រង់ប្រកបដោយគុណធម៌មិនលោភលន់ នាងបានប្រគល់កញ្ចប់នេះអោយខ្ញុំអ្នកទុកដើម្បីប្រគល់អោយអ្នកប្រុសម៉ូដែនវិញពេលអ្នកប្រុសដឹងខ្លួន ។ ខ្ញុំបានរក្សាមាសពេជ្រនេះយ៉ាងសម្ងាត់មិនអោយអ្នកណាដឹងទេ ដើម្បីយកមកប្រគល់អោយដល់ដៃក្រុមគ្រួសារអ្នកប្រុសវិញ ។

អ្នកស្រីអោតាកាន់កញ្ចប់មាសពេជ្រ ដោយរំភើបក្នុងចិត្តនឹកសរសើរចំពោះទឹកចិត្តល្អប្រពៃរបស់នាងធា ហើយអ្នកស្រីពុំអាចលាក់បាំងនូវសមានចិត្តចំពោះនាង



ម៉ាប់ផងដែរ ។ អ្នកស្រីក៏គិតក្នុងចិត្តមិនចេញស្ដីថា ៖ "នាងម៉ាប់នេះសមណាស់បាននៅបំរើក្នុងផ្ទះអញ ព្រោះមនុស្សស្មោះត្រង់ដូចនាងកម្រមាន " ។ នាងម៉ាប់ខំសម្លឹងមើលអ្នកស្រីដែលស្ងៀមស្ងាត់មិនចេញស្ដីមួយស្របក់ធំ ទើបអ្នកស្រីមានប្រសាសន៏ថា ៖

_ចំពោះអំពើល្អដែលនាងបានប្រគល់កញ្ចប់មាសពេជ្រនេះអោយខ្ញុំ !ខ្ញុំអរគុណណាស់ រឿងតំលៃមាសពេជ្រនេះ វាមិនសំខាន់ស្មើនិងទឹកចិត្តស្មោះត្រង់សុចរិតរបស់នាងនិងនាងធានោះទេ ។តែខ្ញុំមិនអោយនាងបង់ខាតទទេចំពោះអំពើល្អដែលនាងបានធ្វើចំពោះខ្លួនខ្ញុំនិងកូនប្រុសខ្ញុំដែរ ព្រោះថាអំពើល្អយ៉ាងណាក៏ត្រូវមានការទូទាត់ដែរ ។ ខ្ញុំនិងផ្ដល់រង្វាន់អោយនាង និងនាងធាវិញយ៉ាងសមរម្យពេលណាមួយមិនខាន ។ តែពេលនេះបើនាងពេញចិត្ត នាងអាចសំណាក់នៅទីនេះ បណ្ដោះអាសន្នសិនក៏បានឬក៏ចាកចេញទៅក៏បាន.....។

នាងម៉ាប់អោនសំពះលោកស្រីហើយពោលទាំងទឹកភ្នែកគ្រែកអរថា ៖

_លោកស្រីអើយ ! បើលោកស្រីមេត្តាសណ្ដោសខ្ញុំអោយសំណាក់នៅទីនេះខ្ញុំអរគុណណាស់ហើយ ខ្ញុំមិនចង់បានសគុណអ្វីពីលោកស្រីទេ សុំតែមួយរស់ប៉ុណ្ណោះ ព្រោះខ្ញុំគ្មានញាតិមិត្តជិតឆ្ងាយឯណាពឹងពាក់ទេ មានតែខ្លួនមួយម៉ង់ៗ ។

ពូជិមដែលអង្គុយលើឥដ្ឋការ៉ូក្បែរនោះដែរក៏ឆ្លៀតសួរអ្នកស្រីថា ៖

_លោកស្រីចុះចំណែកនាងធាតើខ្ញុំបាទត្រូវគិតគូរយ៉ាងម៉េចទាន?បើលោកស្រីត្រូវការជួបនាង ខ្ញុំបាទនិងនាំនាងមកជួបលោកស្រីបាទ !

_ទេ ! មិនបាច់នាំនាងមកទីនេះទេពូ !ពូយកប្រាក់ពីខ្ញុំ ៥០ដុល្លានេះទៅអោយនាង . ហើយពូលែលកបញ្ជូននាងត្រឡប់ទៅស្រុកវិញចុះណា ! ឯចំណែកប្រាក់២០ដុល្លានេះខ្ញុំជូនពូជារង្វាន់ ។

ពូជិមទទួលប្រាក់ ៧០ដុល្លាពីលោកស្រីហើយក៏ជំរាបលាលោកស្រីត្រឡប់ទៅផ្ទះវិញ ។

ចំណែកម៉េង និងសារ៉ាន់ក៏យល់ថាខ្លួនអស់ភារកិច្ចត្រូវនៅទីនេះដែរ ក៏ជំរាបលាអ្នកស្រីត្រឡប់ទៅវិញ ម្យ៉ាងទៀតម៉េងត្រូវបើកឡានជូនពូជិមនិងកម្មករពីរនាក់ត្រឡប់ទៅឃ្លាំងវិញផង ។

ពូជិមឡើងអង្គុយក្នុងឡានឥតនិយាយស្ដីអ្វីមួយម៉ាត់ឡើយ គាត់នឹកក្នុងចិត្តថាឱ ! ហេតុតែគេអ្នកមានគេរិះគេថាំម្លឹងៗបានគេធ្វើអ្នកមានបាន នឹកទៅគួរអាណិតនាងធា និងនាងម៉ាប់ហេតុតែគ្នាក្រហើយមានគំនិតស្មោះត្រង់ ខំរើសបានមាសពេជ្រ១ក្បង់ដៃថ្លៃរាប់ម៉ឺនដុល្លាមិនហ៊ានលបលាក់ទុកទេ សុខចិត្តយកមកប្រគល់អោយម្ចាស់គេវិញ សមតែម្ចាស់គេនោះអោយសគុណគ្នាបានក្រាសក្រែលបន្ដិចតែនេះបែជាអោយគ្នាបន្តិចបន្តួចសោះនិងខាន ។ ហ៊ឺគិតទៅមនុស្សយើងតែក្រៈហើយ អំពើល្អស្មោះត្រង់យ៉ាងណាក៏ចុះថ្លៃតាមនោះដែរ ។

..................................

នាងធាកាន់កាបូបស្បែកតូចមួយ សល់តែខោអាវ ១ចង្កេះឆ្អេះនិងខ្លួននៅឈរមុខខ្ទមជាមួយមីងសៅចាំមើលផ្លូវពូជិមត្រឡប់មកវិញ ។

ពេលរថយន្តម៉េងមកដល់ពូជិមត្រញាប់ប្រញាល់នាំនាងធាឡើងឡានទៅបេនឡានតាក់ស៊ី ។នាងធាសំពះលាមីងសៅទាំងទឹកភ្នែកដោយថ្លែងអំណរគុណមីង ឯមីងជូនពរនាងអោយបានប្រកបដោយសេចក្ដីសុខតាមផ្លូវ ហើយបានទៅជួបម្ដាយនាងវិញ ។មីងបានទូន្មាននាងអោយប្រយ័ត្នខ្លួនឈប់ចាញ់បោកអ្នកណាទៀត ដែលមិនធ្លាប់

សាវតាហើយគេឃោសនាបញ្ចុះបញ្ចូល នាំមករកការងារធ្វើនៅទីក្រុងភ្នំពេញ ។

ពេលមកដល់បេនឡានតាក់ស៊ីផ្សារថ្មី ពូជិម ម៉េង និងសាវ៉ាន់បាននាំនាងទៅ ផ្ទាំផ្ញើនិងអ្នកធ្លាប់ស្គាល់គ្នាម្នាក់ជាតៃកុងតាក់ស៊ីកំពង់ចាម ដែលពូជិមធ្លាប់រាប់អានជិតដិតពីមុនមក ។ ពូជិមប្រគល់ប្រាក់៥០ដុល្លាដែលលោកស្រីភោគាបានអោយដល់ដៃនាងផងប្រាក់២០ដុល្លាទៀតជាចំណែកគាត់ .គាត់ក៏បានអោយទៅនាងដែរ ។ឯម៉េងនិងសាវ៉ាន់បានដកប្រាក់ពីហោប៉ៅម្នាក់១ម៉ឺនរៀលអោយនាងថែមទៀត ។នាងធាមាន់ទឹកភ្នែករលីងរលោងជាប់ជានិច្ច នាងសំពះថ្លែងអំណរគុណអ្នកទាំងអស់គ្នាដែលបានយកចិត្តទុកដាក់ចំពោះនាង ។ នារីកំសត់លូកដៃក្នុងកាបូបនាងយកចិញ្ចៀនពេជ្រ ១វង់ភ្លឺផ្លេកៗប្រគល់អោយអ្នកទាំងបីនាក់ ដោយពោលទាំងទឹកភ្នែកថា៖

_ចិញ្ចៀនពេជ្រ ១វង់នេះជារបស់បងម៉ូដែលគាត់បានអោយខ្ញុំ ឥឡូវខ្ញុំសូមអោយពូអាណិតមេត្តាយកចិញ្ចៀននេះប្រគល់អោយគាត់វិញផង ហើយសូមផ្តាំជំរាបបងម៉ូដែលថាខ្ញុំសូមលាគាត់ហើយ ក្នុងជីវិតនេះខ្ញុំគ្មានថ្ងៃបានជួបមុខគាត់ទៀតទេ ។

ពូជិមក៏អោយយោបល់នាងវិញថា ពាក្យបណ្តាំរបស់នាងចំពោះក្មួយម៉ូដែលចាំពូនិងប្អូនម៉េងយកទៅជំរាបក្មួយម៉ូដែលអោយ តែចំពោះចិញ្ចៀនពេជ្រ ១វង់នេះពូពុំអាចទទួលបញ្ញើក្មួយបានទេ តាមយោបល់ពូចិញ្ចៀននេះ ម៉ូដែលគេអោយក្មួយហើយ និងដោយសុទ្ធចិត្តទៀតផង ក្មួយត្រូវតែរក្សាវាទុកជាប់និងខ្លួនជាសម្បត្តិផ្ទាល់របស់ក្មួយទៅចុះ មិនបាច់ប្រគល់អោយម្ចាស់គេវិញទេ ម្យ៉ាងទៀតក្មួយស្រីទើបនិងរើសបានមាសពេជ្ររបស់គេ ១កញ្ចប់ប្រគល់អោយម្ចាស់គេវិញដែរ ថ្ងៃក្រោយបើមានបញ្ហាអីពូនិងជួយធ្វើជាសាក្សីដល់ក្មួយ ។

នារីកំសត់បានទទួលយោបល់ពីអ្នកទាំងអស់គ្នាដូច្នេះ ក៏ទុកចិញ្ចៀនក្នុងកាបូបវិញហើយសំពះលាជាចុងក្រោយ ។

ទាំងពូជិម ទាំងម៉េងនិងសាវ៉ាន់សឹងតែទប់ទឹកភ្នែកមិនបាន ពេលដែលឃើញតាក់ស៊ីកំពង់ចាមចាកចេញទៅ នាំទាំងនារីកំសត់ទៅផង ។

កូនដៃតូចៗបក់រវិចតាមទ្វារឡានជាសញ្ញាលាហើយអ្នកទាំងអស់គ្នាលាហើយភ្នំពេញ.....។

..............................

